# តារាងព្យញ្ជនៈភ្ជាប់រូបភាព និងកាតព្យញ្ជនៈភ្ជាប់រូបភាព

## តារាងព្យញ្ជនៈភ្ជាប់រូបភាព

[អាយុគោលដៅ]

សម្រាប់កុមារចាប់ពីអាយុ៣ឆ្នាំឡើងទៅ។

[គោលបំណង]

១. ឱ្យកុមារទទួលបាននូវបទពិសោធន៍ក្នុងការដកយកតារាងចេញមកប្រើប្រាស់បណ្តើរ សន្ទនាយ៉ាងសប្បាយរីករាយលើតារាងព្យញ្ជនៈភ្ជាប់រូបភាពបណ្តើរ

២. ឱ្យកុមារស៊ាំនឹងតួព្យញ្ជនៈតាមរយៈរូបភាពដែលគេស្គាល់

៣. ឱ្យកុមារស្តាប់សូរសំលេងរបស់ព្យញ្ជនៈនីមួយៗបានត្រឹមត្រូវ។

[របៀបបង្ហាញទៅកុមារ]

១. ឱ្យកុមារលេងម្នាក់ឯង ឬលេងជាក្រុម ដោយមើលតារាងព្យញ្ជនៈភ្ជាប់រូបភាពបណ្តើរ ឱ្យកុមារស្គាល់ឈ្មោះត្រឹមត្រូវរបស់រូបភាពបណ្តើរ និងស្តាប់សូរសំលេងត្រឹមត្រូវរបស់តួព្យញ្ជនៈនីមួយៗបណ្តើរ។ តាមរយៈរូបភាពនេះ កុមារអាចទទួលបទពិសោធន៍តាមរយៈវិញ្ញាណទាំងប្រាំបណ្តើរ និងអាចសន្ទនាយ៉ាងសប្បាយរីករាយបណ្តើរ។

២. ប្រសិនបើមានកុមារដែលមិនចូលចិត្តនិយាយស្តី សូមគ្រូយកចិត្តទុកដាក់ដោយបបួលកុមារនោះ ឱ្យចូលលេងនិងសន្ទនាសប្បាយជាមួយមិត្តភ័ក្តិផង។

៣. សូមគ្រូយកម្រាមដៃចង្អុលរូបភាព រួចអានឈ្មោះរូបភាពនោះឱ្យកុមារស្តាប់ម្តងមួយៗ។

៤. បន្ទាប់មកសូមគ្រូយកម្រាមដៃចង្អុលរូបភាពមួយ រួចសួរកុមារថាតើនេះជារូបភាពអ្វី ហើយឱ្យកុមារឆ្លើយ។ (សូមយល់ឱ្យបានច្បាស់អំពីភាពខុសគ្នារបស់៣ និង៤)

[ចំណុចត្រូវប្រុងប្រយ័ត្ន]

១. សូមគ្រូយកចិត្តទុកដាក់បញ្ចេញសូរសំលេងឱ្យបានត្រឹមត្រូវអោយកុមារស្តាប់។

២. សូមគ្រូបញ្ជាក់ថាតើកុមារស្គាល់(ធ្លាប់ឃើញ)រូបភាពរបស់តួព្យញ្ជនៈទាំង៣៣តួដែរឬយ៉ាងណា។ ចំពោះកុមារដែលមានបទពិសោធន៍តិច សូមគ្រូបង្ហាញរបស់ជាក់ស្តែងប្រសិនបើមាន។

៣. សូមប្រុងប្រយ័ត្នអំពីកន្លែងដែលព្យួរតារាងព្យញ្ជនៈភ្ជាប់រូបភាពនេះ ។ ( សូមព្យួរនៅកន្លែងដែលមានពន្លឺគ្រប់គ្រាន់ និងព្យួរត្រឹមកំពស់ភ្នែកកុមារ ) ។

៤. សូមព្យួរតារាងព្យញ្ជនៈភ្ជាប់រូបភាពនេះនៅកន្លែងមួយក្នុងបន្ទប់ ( ចៀសវាងព្យួរលាយឡំជាមួយតារាងផ្សេង ព្រោះចាំបាច់ត្រូវទាក់ទាញកុមារឱ្យមើលឱ្យបានច្រើន ) ។

[ចំណុចល្អរបស់តារាងព្យញ្ជនៈភ្ជាប់រូបភាព]

១. រូបភាពស្អាតទាំងនេះត្រូវបានគូរដោយជនជាតិខ្មែរ ។

២. រូបភាពសាមញ្ញហើយច្បាស់ដែលអាចឱ្យកុមារងាយយល់ឆាប់ស្គាល់របស់ ។ ( មិនមានលាយស្រមោលនៃរូបភាពផ្សេងឡើយ ) ។

៣. គ្រូអាចប្រើប្រាស់ជាមួយកុមារម្នាក់ក៏បាន ប្រើប្រាស់ជាក្រុមក៏បាន ។

៤. កុមារអាចស៊ាំជាមួយព្យញ្ជនៈទាំង៣៣តួដោយសប្បាយរីករាយ ។

## <u>កាតព្យញ្ជនៈភ្ជាប់រូបភាព</u>

[អាយុគោលដៅ]

សម្រាប់កុមារចាប់ពីអាយុ៣ឆ្នាំឡើងទៅ និងជាកុមារដែលមានបទពិសោធន៍ជាមួយតារាងព្យញ្ជនៈភ្ជាប់រូបភាព ។

[គោលបំណង]

១. ឱ្យកុមារដឹងថារូបភាពនៃកាតទាំង៣៣សន្លឹកដូចរូបភាពក្នុងតារាងព្យញ្ជនៈភ្ជាប់រូបភាព

២. បង្កើនកំលាំងប្រមូលផ្តុំរបស់កុមារ

៣. ឱ្យកុមារទទួលបទពិសោធន៍ជាមួយល្បែងដែលមានវិន័យដោយសប្បាយរីករាយ

៤. ឱ្យកុមារមានភាពស៊ាំជាមួយតួព្យញ្ជនៈ ។ ( បំលែងពីរូបភាពមកតួព្យញ្ជនៈ )

[របៀបបង្ហាញទៅកុមារ]

លេងម្នាក់ឯង ឬលេងជាក្រុម៥-៦នាក់

១. ផ្កាប់កាតទាំង៣៣ រួចដាក់នៅចំកណ្តាល

១.១. កំណត់លេខរៀងអ្នកបើក ( អ្នកប៉ាវឈ្នះបើកមុន រួចអ្នកបន្តតាមលេខរៀងខាងស្តាំឬខាងឆ្វេងអ្នកឈ្នះ ) : បើកកាតខាងលើម្តងម្នាក់ៗ ។ ពេលបើកកាតនីមួយៗ ឱ្យអ្នកបើកអានឈ្មោះរូបភាពឱ្យបានត្រឹមត្រូវ រួចយកទៅដាក់នៅខាងមុខខ្លួន ។

១.២. ក្រោយពេលបើកកាតទាំង៣៣សន្លឹករួចហើយ អាចលេងសារឡើងវិញម្តងទៀតបានប្រសិនបើចង់។

២. យកកាតទាំង៣៣សន្លឹកទៅបើកពង្រាយនៅលើកន្ទេល ឬលើតុ

២.១. គ្រូមើលកាត១សន្លឹកក្នុងចំណោមកាតទាំង៣៣សន្លឹក រួចអានឈ្មោះរូបភាពនៃកាតនោះឱ្យបានត្រឹមត្រូវឱ្យកុមារស្តាប់។

២.២. ពេលកុមារស្តាប់គ្រូអានឈ្មោះកាតចប់រួច ត្រូវយកដៃទៅខ្ទប់កាតនោះភ្លាម អ្នកណាខ្ទប់បានមុនអ្នកនោះអាចយកកាតនោះមកធ្វើជារបស់ខ្លួនបាន។

២.៣. ធ្វើតាមរបៀប២.១. និង២.២. សារចុះសារឡើងរហូតដល់អស់កាត។ ពេលអស់កាតហើយ ឱ្យកុមាររាប់កាតដែលខ្លួនឆក់បានម្តងម្នាក់ៗ។ អ្នកណាឆក់បានកាតច្រើនជាងគេ អ្នកនោះជាអ្នកឈ្នះ។

៣. លេងដូចរបៀបលេងទី២ ប៉ុន្តែដូរពីហៅរូបភាពមកហៅតួព្យញ្ជនៈវិញ ដោយឱ្យកុមារស្តាប់សូរព្យញ្ជនៈរួចហើយខ្ទប់កាតដែលមានតួព្យញ្ជនៈនោះ។

[ចំណុចត្រូវប្រុងប្រយ័ត្ន]

១. សូមគ្រូយកចិត្តទុកដាក់បញ្ចេញសូរសំលេងឱ្យបានត្រឹមត្រូវឱ្យកុមារស្តាប់។

២. ពន្យល់កុមារអំពីវិន័យនៃល្បែងឱ្យបានត្រឹមត្រូវ រួចឱ្យកុមារលេងដោយគោរពវិន័យយ៉ាងសប្បាយរីករាយ។

៣. ការលេងដោយហៅតួព្យញ្ជនៈ(លេងតាមរបៀបទី៣) ត្រូវលេងដោយក្រុមកុមារដែលចេះអានតួព្យញ្ជនៈ។

៤. សម្រាប់កុមារដែលមានបញ្ហាខ្សោយ គ្រូត្រូវជួយបន្ថែមប្រកបដោយភាពទន់ភ្លន់។

[ចំណុចល្អរបស់កាតព្យញ្ជនៈភ្ជាប់រូបភាព]

១. កុមារអាចលេងដោយប្រើប្រាស់ដៃរបស់ខ្លួន។

២. កុមារមានឱកាសស្តាប់សូរសំលេងត្រឹមត្រូវរបស់ព្យញ្ជនៈនីមួយៗបានច្រើនដង។

៣. កុមារអាចស៊ាំនឹងល្បែងដែលមានវិន័យងាយៗ ហើយអាចលេងយ៉ាងសប្បាយរីករាយជាក្រុមបាន។

៤. កុមារអាចទទួលបទពិសោធន៍ក្នុងការរាប់ចំនួនបាន។

## ល្បែងប្រើតារាងព្យញ្ជនៈភ្ជាប់រូបភាពជាមួយកាតព្យញ្ជនៈភ្ជាប់រូបភាព

[អាយុគោលដៅ]

សម្រាប់កុមារចាប់ពីអាយុ៣ឆ្នាំឡើងទៅ និងជាកុមារដែលធ្លាប់ប្រើប្រាស់តារាងព្យញ្ជនៈភ្ជាប់រូបភាព និងកាតព្យញ្ជនៈភ្ជាប់រូបភាព។

[គោលបំណង]

១. បង្កើតកំលាំងវិនិច្ឆ័យរបស់កុមារ ដោយឱ្យកុមារស្វែងរករូបភាពដូចគ្នា រួចយកទៅផ្ទៀងផ្ទាត់ ហើយវិនិច្ឆ័យអំពីភាពដូចគ្នា និងភាពខុសគ្នាបាន

២. បង្កើនកំលាំងប្រមូលផ្តុំរបស់កុមារ

៣. ឱ្យកុមារស្តាប់សូរសំលេងត្រឹមត្រូវនៃឈ្មោះរបស់នីមួយៗ

៤. ឱ្យកុមារស្តាប់សូរសំលេងត្រឹមត្រូវនៃតួព្យញ្ជនៈនីមួយៗ។

[របៀបបង្ហាញទៅកុមារ]

លេងម្នាក់ឯង ឬលេងជាក្រុមតូច

១. លេងនៅលើកន្ទេល ឬនៅលើតុ ដោយរំលឹកឡើងវិញនូវអ្វីដែលបានរៀនកន្លងមកលើតារាងព្យញ្ជនៈភ្ជាប់រូបភាព

១.១. យកកាតព្យញ្ជនៈភ្ជាប់រូបភាពដាក់ក្បែរតារាងព្យញ្ជនៈភ្ជាប់រូបភាព ដោយផ្កាប់កាតទាំងនោះ ហើយកំណត់លេខរៀងអ្នកបើក(អ្នកបាវឈ្នះបើកមុន រួចអ្នកបន្តតាមលេខរៀងខាងស្តាំឬខាងឆ្វេងអ្នកឈ្នះ)។

១.២. បើកកាតតាមលេខរៀងម្តងម្នាក់ម្តង១សន្លឹក រួចអានឈ្មោះរូបភាពនៃកាតដែលបើក ហើយស្វែងរករូបភាពដែលដូចគ្នានៅលើតារាងព្យញ្ជនៈភ្ជាប់រូបភាព ពេលឃើញហើយដាក់កាតនោះពីលើ។

១.៣. បើកកាតព្យញ្ជនៈភ្ជាប់រូបភាព៣៣សន្លឹក ដោយបញ្ចេញសូរសំលេងម្តង១សន្លឹកពេលបើក។

១.៤. គ្រូអានព្យញ្ជនៈឱ្យកុមារស្តាប់ រួចឱ្យកុមារអានតាម។

[ចំណុចត្រូវប្រុងប្រយ័ត្ន]

១. យឺតៗ ទន់ភ្លន់

២. អានសូរសំលេងនៃតួព្យញ្ជនៈឱ្យច្បាស់ៗ។

[ចំណុចល្អរបស់ល្បែង]

១. កុមារអាចបង្កើតកំលាំងវិនិច្ឆ័យនិងសមត្ថភាពពិចារណាតាមរយៈការវិនិច្ឆ័យដោយខ្លួនឯងសារចុះសារឡើង។

២. បង្កើនសាមគ្គីភាព និងភាពអំណត់របស់កុមារតាមរយៈការលេងជាក្រុម។

៣. តាមរយៈការដាក់កាតលើតារាងព្យញ្ជនៈភ្ជាប់រូបភាពត្រង់កន្លែងដែលមានរូបដូចគ្នា (កុមារវិនិច្ឆ័យខ្លួនឯង) អាចបង្កើតបាននូវកំលាំងវិនិច្ឆ័យរបស់កុមារបាន។